# អ្នកការពារសិទ្ធិមនុស្ស
# អ្នកស្រី ទឹម សាក់មុន្នី

ដោះលែង ១៥ នាក់
បញ្ឈប់អំពើហិង្សា

## ជាប់ពន្ធនាគារព្រោះការទាមទារសិទ្ធិលើផ្ទះសម្បែង

### ពត៌មានសង្ខេប

អាយុ៖ ៦៤ ឆ្នាំ
សហគមន៍៖ បុរីកីឡា
ថ្ងៃចាប់ខ្លួន៖ ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១២
ថ្ងៃជំនុំជម្រះ៖ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២
ពន្ធនាគារ៖ មណ្ឌលអប់រំកែប្រែទី២ (ព្រៃស)
ផ្តល់នាមជាអ្នកទោសនៃមនសិការ ដោយអង្គការ លើកលែងទោសអន្តរជាតិ

//////////////////////////////////

កាលពីដើមខែកញ្ញា ឆ្នាំ២០១២ អ្នកស្រី ទឹម សាក់មុន្នី ដែល មានអាយុ ៦៤ ឆ្នាំ ត្រូវបានហៅទៅជួបឧកញ៉ា ស៊ុយ សុផាន។ អ្នកស្រី ស៊ុយ សុផាន គឺជាម្ចាស់ក្រុមហ៊ុន ផាន អ៊ីមិច ដែលជាក្រុមហ៊ុនទទួលខុសត្រូវក្នុងការបណ្តេញចេញដោយបង្ខំលើគ្រួសារអ្នកស្រី ទឹម សាក់មុន្នី ពីផ្ទះនៅតំបន់បុរីកីឡា និងបំផ្លាញរាល់របស់របរ របស់អ្នកស្រីសាក់មុន្នី។

អ្នកស្រី ស៊ុយ សុផាន បានផ្តល់ឲ្យកូនប្រុសអ្នកស្រី ទឹម សាក់មុន្នី ចំនួន ១.០០០ ដុល្លារ ជាសំណង និងកូនផ្ទះតូចមួយនៅតំបន់ទីលំនៅថ្មីទួលសំបូរ ដែលមានចម្ងាយ ២៥គីឡូម៉ែតពីរាជធានីភ្នំពេញ។ លោកបានបដិសេធទទួលយកសំណងនេះ។ ប៉ុន្មានថ្ងៃក្រោយមក អ្នកស្រី ទឹម សាក់មុន្នី ត្រូវបានចាប់ខ្លួន។

អ្នកស្រីទឹម សាក់មុន្នី គឺជាអ្នកតំណាងដ៏លេចធ្លោម្នាក់ នៃសហគមន៍បុរីកីឡា នៅក្នុងជម្លោះដីធ្លីដ៏រាំរៃជាមួយក្រុមហ៊ុន ផាន អ៊ីមិច។ គ្រួសាររបស់អ្នកស្រី គឺជាគ្រួសារមួយក្នុងចំណោមគ្រួសារដែលត្រូវបានបណ្តេញចេញ (ដោយមានសំណងតិចតួច ប្រសិនបើ មាន) ពីតំបន់បុរីកីឡា បន្ទាប់ពីក្រុមហ៊ុន ផាន អ៊ីមិច បានរំលោភលើ កិច្ចសន្យាសាងសង់អគារ ចំនួន ១០ នៅតំបន់បុរីកីឡា សម្រាប់ គ្រួសារ ពួថ្ម ដោយសង់ត្រឹមតែចំនួន ៨ អគារប៉ុណ្ណោះ។

បន្ទាប់ពីពួកគេត្រូវបានបណ្តេញចេញពីផ្ទះរបស់ពួកគេ កាលពីខែមករា ឆ្នាំ២០១២ អ្នកស្រី ទឹម សាក់មុន្នី ជាមួយនឹងកូនប្រុសរបស់ អ្នកស្រីឈ្មោះ អួន គង់ភិនាថ និងកូនភ្លោះរបស់លោក ដែលមានអាយុ ១២ ឆ្នាំ បានរស់នៅជាមួយនឹងរបស់របរបន្តិចបន្តួច ដែលសេសសល់នៅលើគ្រែពីរជាន់តូចមួយនៅក្រោមកាំជណ្តើរ នៅតំបន់បុរីកីឡា។ អ្នកស្រីសំរាន្តនៅគ្រែជាន់ក្រោមជាមួយចៅភ្លោះ ហើយកូនប្រុសរបស់អ្នកស្រីសំរាន្តនៅលើគ្រែជាន់លើ។

អ្នកស្រី ទឹម សាក់មុន្នី ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី៥ ខែកញ្ញា។ អាជ្ញាធរបានអះអាងថា អ្នកស្រី បានធ្វើការ "អះអាងដោយខុស" នៅក្នុងការព្យាយាមទទួលបានផ្ទះក្នុងអគារ សម្រាប់កូនប្រុសរបស់អ្នកស្រី។ បណ្តឹងប្រឆាំងនឹងអ្នកស្រីត្រូវបានដាក់ដោយអ្នកស្រី ស៊ុយ សុផាន។

អ្នកស្រី ទឹម សាក់មុន្នី បច្ចុប្បន្ន កំពុងស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្ននៅពន្ធនាគារព្រៃស (មណ្ឌលអប់រំកែប្រែទី២ ឬ ម២) នៅរាជ ធានីភ្នំពេញ។ អ្នកស្រីនឹងត្រូវបានជំនុំជម្រះនៅសាលាដំបូងរាជធានីភ្នំពេញ នាម៉ោង ២ រសៀល នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២។ ប្រសិន បើរកឃើញពិរុទ្ធភាព អ្នកស្រីនឹងប្រឈមមុខនឹងការជាប់ពន្ធនាគាររយៈពេលរហូតដល់ ២ឆ្នាំ ហើយពិន័យ



អ្នកស្រីទឹម សាក់មុន្នី ដើមឆ្នាំ២០១២

ជាប្រាក់ចាប់ពី ១ លាន ទៅ ៤លានរៀល(២៥០-១.០០០ដុល្លារ)។

មិនមានភាពចៃដន្យនោះទេ ដែលអ្នកស្រី ទឹម សាក់មុន្នី ត្រូវបានចាប់ខ្លួននៅថ្ងៃបន្ទាប់ បន្ទាប់ពីសកម្មជនដីធ្លីដ៏លេចធ្លោរម្នាក់ផ្សេងទៀត គឺអ្នកស្រី យ៉ោម បុប្ផា មកពីសហគមន៍បឹងកក់ទទួលវាសនាដូចគ្នា។ ស្ត្រីទាំងពីរក្លាយជាបន្លាយ៉ាងច្បាស់នៅក្នុង កែវភ្នែករបស់ អាជ្ញាធរ និងអ្នកមានអំណាចការពារផលប្រយោជន៍ផ្ទាល់ខ្លួន (អ្នកជំនួញស្តុកស្តម្ភស្រី និងប្រុស ដែលមានអំណាចទាំងឡាយ ហើយដែលមានទំនាក់ទំនងជិតស្និទ្ធិនឹងគណបក្សកាន់អំណាច)។ វាមានភាព ច្បាស់ណាស់ថា ស្ត្រីបានក្លាយជាជនរងគ្រោះពីយុទ្ធសាស្ត្រក្នុងការបំភិតបំភ័យ និងបំបិទមាត់បណ្តាញនៃសកម្មជនដីធ្លីដែលកំពុងតែរីកដុះដាលនៅកម្ពុជា។

វាក៏មិនមែនជាភាពចៃដន្យដែរ ដែលចាប់តាំងពីការចាប់ខ្លួនរបស់អ្នកស្រីបុគ្គលិកក្រុមហ៊ុនផាន អ៊ីមិច បានប្រើប្រាស់ការចាប់ខ្លួនរបស់អ្នកស្រីមកគម្រាមកំហែងចាប់ខ្លួនសមាជិកដទៃទៀតនៃសហគមន៍បុរីកីឡា។

ទាំងអ្នកស្រីយ៉ោម បុប្ផា និងអ្នកស្រី ទឹម សាក់មុន្នី ត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ដោយគ្មានហេតុផលចាប់តាំងពីខែកញ្ញា (វិធានការណ៍មួយដែលគួរតែត្រូវបានប្រើប្រាស់នៅក្នុងតែករណី "លើកលែង" ដូចជាដើម្បីបញ្ឈប់បទល្មើសផ្សេងទៀតកើតឡើង ដើម្បីការពារការ បំពានលើសាក្សី ឬជនរងគ្រោះ ឬ ដើម្បីការពារសណ្តាប់ធ្នាប់សាធារណៈ)។ ចំពោះករណី

*"ប្រសិនបើមិនទទួលយកសំណង យើងនឹងចាប់ខ្លួនស្ត្រីម្នាក់ពីសហគមន៍របស់អ្នក ដើម្បីបន្ទាចដល់អ្នកដទៃ"*
-អ្នកតំណាងក្រុមហ៊ុនដែលមិនបញ្ចេញឈ្មោះ

ទាំងអស់នេះ គឺច្បាស់ណាស់មិនអាចយកមកអនុវត្តលើករណីរបស់ពួកគេនោះទេ។

នៅខណៈដែលម្តាយដ៏ល្ងិតល្ងៃរបស់លោកនៅក្នុងពន្ធនាគារ លោក អួន គង់ភិនាថ ដែលមានអាយុ ៥៥ ឆ្នាំ បានកំពុងព្យាយាមផ្គត់ផ្គង់ជីវភាពនៅក្នុងគ្រួសារ និងមើលថែរក្សាកូនភ្លោះទាំងពីររបស់លោក។

ឋានៈជានាយទាហានតាំងពីអាយុ ១៥ ឆ្នាំ លោកបានទទួលរងជំងឺពិការជើងជាអចិន្ត្រៃយ៍ ដែលបណ្តាលមកពីអំបែងគ្រាប់ និងបញ្ហាផ្នែកក្បាលនៅពេលគាត់មានអាយុ ១៨ ឆ្នាំ។ ទោះជាទទួលរងរបួស បែបនេះ លោកក៏នៅតែបន្តធ្វើការក្នុងជួរទាហាន ក្នុងឋានៈជាអ្នក រដ្ឋបាល រហូតដល់លោកចូលនិវត្តន៍ដោយសារភាពពិការរបស់លោក នៅពេលលោកមានអាយុ ៣៦ ឆ្នាំ។ លោក មិនអាចរកការងារចាប់តាំងពីពេលនោះមក។ លោកក៏មានរោគរបេងដែលតម្រូវឲ្យមានការថែទាំផ្នែកវេជ្ជសាស្ត្រផងដែរ។

ដោយការចាកចេញពីជួរកងទ័ព លោកបានទទួលនូវកញ្ចប់ប្រាក់ចូលនិវត្តន៍បន្តិចបន្តួច ដែលលោកបានយកទៅទិញដីទំហំ ៥x៧ ម៉ែត្រការ៉េ ដើម្បីសាងសង់ផ្ទះនៅក្នុងតំបន់បុរីកីឡា នៅជិតកន្លែងដែលម្តាយរបស់លោកទើបតែផ្លាស់មកនៅ។ កូនភ្លោះរបស់លោកម្នាក់ស្រី និងម្នាក់ទៀតប្រុសកើតនៅខែវិច្ឆិកា ឆ្នាំ២០០០ (ម្តាយរបស់ ពួកគេបានស្លាប់ ៧ ថ្ងៃក្រោយកំណើតរបស់ពួកគេ)។

អ្នកស្រី ទឹម សាក់មុន្នី ត្រូវបានបណ្តេញចេញពីផ្ទះរបស់អ្នកស្រីនៅក្នុងតំបន់បុរីកីឡា នៅឆ្នាំ២០០៧ និងត្រូវបានផ្តល់ផ្ទះក្នុងអគារជំនួស ដែលក្រោយមកអ្នកស្រីបានលក់ផ្ទះនោះ ដើម្បីជួយផ្គត់ផ្គង់កូនប្រុស និងចៅប្រុសភ្លោះរបស់អ្នកស្រី។ អ្នកស្រីបានរស់នៅជាមួយកូនប្រុស និងចៅភ្លោះរហូតដល់មានការបណ្តេញចេញនៅ ខែមករា ឆ្នាំ២០១២។ ជាស្ត្រីមេម៉ាយ (ស្វាមីរបស់អ្នកស្រីបានស្លាប់ក្នុងអំឡុងពេលរបបខ្មែរក្រហម) អ្នកស្រី គឺជាអ្នកមើលថែរក្សា និង អ្នករកចំនូលដ៏សំខាន់ម្នាក់ សម្រាប់គ្រួសារ។

ចាប់តាំងពីមានការចាប់ខ្លួនអ្នកស្រី គ្រួសារអ្នកស្រីបានពឹងផ្អែកលើជំនួយពីសហាគមន៍បុរីកីឡា និងអង្គការមិនមែនរដ្ឋាភិបាលនានា។ កូនភ្លោះក៏បានជួយរកចំនូលសម្រាប់គ្រួសារ ដោយដើរប្រមូលសំបកកំប៉ុង និងដបទទេពីតាមផ្លូវ យកទៅលក់។ ពួកគេក្រោកពីដេក នៅម៉ោង ៥ ព្រឹក ដើម្បីទៅរកប្រាក់មួយចំនួនមុនពេលទៅសាលា រៀន។ ទោះជាមានបញ្ហាច្រើនក្នុងគ្រួសារ ចៅភ្លោះទាំងពីរក៏ទទួលបានកំណត់ត្រាល្អពីសាលារៀនផងដែរ។

អ្នកស្រី ទឹម សាក់មុន្នី ត្រូវបានដាក់នៅក្នុងបន្ទប់ជាមួយស្ត្រី ចំនួន ៦២ នាក់ផ្សេងទៀត រួមទាំងអ្នកស្រី យ៉ោម បុប្ផា។ អ្នកស្រី មានបញ្ហា ផ្នែកបេះដូង ហើយអ្នកស្រីក៏បានស្រកទម្ងន់អស់ជាច្រើនចាប់តាំងពីអ្នកស្រីត្រូវបានគេឃុំខ្លួន។

នៅមណ្ឌលអប់រំកែប្រែទី២ ស្ត្រីត្រូវបានគេដាក់ឲ្យស្ថិតក្នុងស្ថានភាពភិតភ័យ គ្មានអនាម័យ កកកុញ ហើយមិនមាន ឬមានការ ផ្តល់សេវាពេទ្យតិចតួច។ អ្នកជាប់ពន្ធនាគារ ត្រូវតែបង់ថ្លៃទំនិញនានា ដូចជាទឹកស្អាតសម្រាប់បរិភោគ និងកន្លែងសម្រាប់ដេក។បន្ទប់មានសភាពក្តៅខ្លាំង ហើយមិនមានពន្លឺធម្មជាតិ និងខ្យល់ចេញចូលបាន គ្រប់គ្រាន់។ អ្នកដែលជាប់ឃុំបណ្តោះអាសន្ន ត្រូវបានគេដាក់នៅក្នុងបន្ទាប់ជាមួយអ្នកដែលត្រូវបានផ្តន្ទាទោសរួច ឬ ដាក់ពិរុទ្ធភាពរួច។

ដូចគ្នានឹងអ្នកស្រី យ៉ោម បុប្ផា អ្នកស្រី ទឹម សាក់មុន្នី ត្រូវបានគេឃុំខ្លួនក្នុងពន្ធនាគារ ក៏ព្រោះតែភាពសកម្មនិយមរឿងដីធ្លីរបស់អ្នកស្រី។ អង្គការលើកលែងទោសអន្តរជាតិ (Amnesty International) បានថ្លែង ថាស្ត្រីទាំងពីររូប គឺជាអ្នកទោសនៃមនសិការ ដែលគួរតែត្រូវបាន ដោះលែងភ្លាមៗ និងមិនមានល័ក្ខខ័ណ្ឌ។ អាជ្ញាធរកម្ពុជា សូមមេត្តាយកចិត្តទុកដាក់លើការអំពាវនាវនេះផង។


អ្នកស្រី ទឹម សាក់មុន្នី និយាយទៅកាន់សាធារណៈជនអំពើសិទ្ធិដីធ្លី និងសិទ្ធិនារី កាលពីខែមិនា ឆ្នាំ២០១២